## សេចក្ដីជូនដំណឹងស្ដីពីឯកជនភាព

ក្រសួងសហគមន៍ និងយុត្តិធម៌នៃរដ្ឋ New South Wales (DCJ) ដំណើរការកម្មវិធី Step Together (បោះជំហានរួមគ្នា) ដែលជាបណ្ដាញទូរសព្ទជំនួយ និងសេវាជំនួយទូទាំងប្រទេសសម្រាប់ទប់ស្កាត់អំពើហិង្សាជ្រុលនិយម ក្នុងនាមឱ្យក្រសួងកិច្ចការផ្ទៃក្នុងរបស់រដ្ឋាភិបាលសហព័ន្ធ (DHA)។ នេះមានន័យថា ក្រសួង DCJ ទទួល និងឆ្លើយតបចំពោះសំណួរ ដែលបានផ្ញើមកកាន់ Step Together (បោះជំហានរួមគ្នា) ពីបណ្ដារដ្ឋ និងដែនដីទាំងអស់របស់អូស្ត្រាលី។

### កាតព្វកិច្ចឯកជនភាពរបស់កម្មវិធី Step Together (បោះជំហានរួមគ្នា) ក្រោមច្បាប់នៃរដ្ឋ New South Wales

ក្នុងនាមជាទីភ្នាក់ងាររដ្ឋាភិបាលនៃរដ្ឋ New South Wales ក្រសួង DCJ ត្រូវតែគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់ឯកជនភាពនៃរដ្ឋ New South Wales នៅពេលដោះស្រាយព័ត៌មានរបស់អ្នក៖

- សម្រាប់ព័ត៌មានផ្ទាល់ខ្លួន៖ *ច្បាប់ការពារឯកជនភាព និងព័ត៌មានផ្ទាល់ខ្លួន ឆ្នាំ 1998* (NSW)
- សម្រាប់ព័ត៌មានសុខភាព៖ *ច្បាប់ស្ដីពីកំណត់ត្រាសុខភាព និងព័ត៌មានឯកជនភាពឆ្នាំ 2002* (NSW)

ច្បាប់ទាំងនេះ មានគោលការណ៍ឯកជនភាព ដែលចែងថា៖

- តើព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសុខភាពអ្វីខ្លះ ដែលយើងអាចប្រមូលបាន និងវិធីប្រមូលព័ត៌មានទាំងនោះ
- វិធីសាស្ត្ររក្សាទុក និងការការពារព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសុខភាព
- វិធីដើម្បីដឹងថា តើព័ត៌មានអ្វីខ្លះ ដែលយើងមានអំពីលោកអ្នក និងរបៀបកែតម្រូវព័ត៌មាននោះ ប្រសិនបើមិនត្រឹមត្រូវ
- វិធីដាក់ពាក្យបណ្ដឹងទាក់ទងនឹងការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានសុខភាពរបស់លោកអ្នក។

### ព័ត៌មានអ្វីខ្លះ ដែលយើងប្រមូល

កម្មវិធី Step Together (បោះជំហានរួមគ្នា) ប្រមូលព័ត៌មានតែពីបុគ្គល ដែលបានទាក់ទងមកកាន់កម្មវិធីនេះប៉ុណ្ណោះ។ ការផ្ដល់ព័ត៌មានអាចធ្វើឡើងតាមរយៈការហៅទូរសព្ទទៅកាន់បណ្ដាញទូរសព្ទជំនួយ ការជជែកតាមគេហទំព័រ ឬតាមរយៈអ៊ីមែល។

នៅពេលដែលមានការហៅទូរសព្ទទៅកាន់បណ្ដាញទូរសព្ទជំនួយ យើងក៏ប្រមូលលេខទូរសព្ទរបស់អ្នកហៅចូលផងដែរ លើកលែងតែវាជាលេខឯកជន រួមទាំងរដ្ឋ ឬដែនដីដែលលោកអ្នកកំពុងហៅចេញផងដែរ។ រាល់ការហៅទូរសព្ទទាំងអស់ទៅកាន់បណ្ដាញទូរសព្ទជំនួយ នឹងត្រូវថតទុក។

### គោលបំណងនៃការប្រមូលព័ត៌មាន និងវិធីប្រើប្រាស់ព័ត៌មាននោះ

សេវាកម្ម Step Together (បោះជំហានរួមគ្នា) ប្រើប្រាស់ព័ត៌មានដែលខ្លួនប្រមូលបាន ដើម្បីឆ្លើយទៅនឹងសំណួរនានាដែលអ្នកអាចមាន ផ្ដល់ដំបូន្មាន និងឬភ្ជាប់អ្នកទៅកាន់សេវាជំនួយដែលពាក់ព័ន្ធ។

យើងក៏ប្រើប្រាស់ព័ត៌មានដែលយើងប្រមូល ដើម្បីវាយតម្លៃលើការសាកសួររបស់អ្នកផងដែរ។ យើងអាចត្រូវចែករំលែកព័ត៌មានរបស់លោកអ្នកជាមួយក្រុមអ្នកឯកទេសនៅក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នកក្នុងស្ថានភាពខ្លះ ដើម្បីឱ្យពួកគេអាចផ្ដល់ការគាំទ្រ និងកម្មវិធីបន្ថែមទៀតដែលមាននៅនឹងកន្លែង។ យើងនឹងជម្រាបជូនលោកអ្នកជាមុនសិន ហើយពិភាក្សាអំពីការចែករំលែកព័ត៌មានរបស់លោកអ្នក។ ព័ត៌មានបន្ថែមអំពីកម្មវិធីនានាដែលមាននៅក្នុងរដ្ឋ ឬដែនដីនីមួយៗមាន នៅទីនេះ។

យើងក៏អាចប្រើប្រាស់ព័ត៌មានរបស់លោកអ្នកជាកម្រិតសរុបផងដែរ ដើម្បីជួយរៀបចំផែនការសម្របសម្រួល និងកែលម្អសេវារបស់កម្មវិធី Step Together។

ក្នុងករណីជាក់លាក់ ក្រសួង DCJ អាចត្រូវបានអនុញ្ញាត ផ្តល់សិទ្ធិ ឬតម្រូវឱ្យបង្ហាញព័ត៌មានមួយចំនួនតាមរយៈច្បាប់។ យើងនឹងធ្វើការចែករំលែកព័ត៌មាននៅក្នុងស្ថានភាពដែលមានហានិភ័យភ្លាមៗចំពោះសុខភាព ឬសុវត្ថិភាពរបស់បុគ្គលណាមួយ ឬក្នុងករណីដែលមានក្តីបារម្ភអំពីសុវត្ថិភាពសុខុមាលភាព ឬសុខភាពរបស់កុមារ។

**ព័ត៌មានបន្ថែមទាក់ទងនឹងការគ្រប់គ្រងព័ត៌មានរបស់កម្មវិធី Step Together**

ការផ្តល់ព័ត៌មានទៅកាន់កម្មវិធី Step Together គឺមានលក្ខណៈស្ម័គ្រចិត្ត ហើយលោកអ្នកជាអ្នកកំណត់ថា ត្រូវចែករំលែកប៉ុន្មានជាមួយយើង។

យើងប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងព័ត៌មាន ដែលយើងប្រមូលបានប្រកបដោយការទទួលខុសត្រូវ និងត្រឹមត្រូវ ព្រមទាំងការពារឯកជនភាពរបស់អ្នកពាក់ព័ន្ធ បុគ្គលិក និងសមាជិកសាធារណជនរបស់យើង។ បុគ្គលិករបស់កម្មវិធី Step Together នឹងរក្សាទុកព័ត៌មានទាំងអស់ ដែលបានប្រមូលដោយសុវត្ថិភាពនៅក្នុងប្រព័ន្ធដែលមានការគ្រប់គ្រង ហើយមានតែពួកគេប៉ុណ្ណោះ ដែលអាចមើលព័ត៌មានទាំងនោះបាន។

សម្រាប់ព័ត៌មានបន្ថែម ដើម្បីស្នើសុំចូលមើល ឬកែតម្រូវព័ត៌មានរបស់លោកអ្នក ឬដើម្បីដាក់ពាក្យបណ្តឹងឯកជនភាព សូមទំនាក់ទំនងទៅ៖

- ទូរសព្ទ៖ 1800 875 205
- អ៊ីមែល៖ contact@steptogether.gov.au

**គោលការណ៍ឯកជនភាពរបស់ DCJ** និង **ផែនការគ្រប់គ្រងភាពឯកជនរបស់ DCJ** គូសបញ្ជាក់ពីរបៀប ដែលក្រសួង *គ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសុខភាព ហើយអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន នៅក្រោមច្បាប់ស្តីពីការការពារឯកជនភាព និងព័ត៌មានផ្ទាល់ខ្លួនឆ្នាំ* 1998 និងច្បាប់ស្តីពី *កំណត់ត្រាសុខភាព និងព័ត៌មានឯកជនភាព ឆ្នាំ 2002។*

ក្រសួងសហគមន៍ និងយុត្តិធម៌នៃរដ្ឋ New South Wales គឺជាអ្នកប្រមូលព័ត៌មានផ្ទាល់ខ្លួន និង

> ព័ត៌មានសុខភាពដែលទទួលបានតាមរយៈកម្មវិធី Step Together។
> Locked Bag 5000
> Parramatta, NSW, 2124